*សេចក្តីព្រាង ដែលបានដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាអ្នកច្បាប់ រវាងថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៧ និងថ្ងៃប្រជុំលើកចុងក្រោយ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៧ ។*

*សេចក្តីព្រាង*

# ច្បាប់
# ស្តីពី
# លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.-

ច្បាប់នេះមានគោលដៅអនុវត្តចំពោះចៅក្រមទូទាំងព្រះរាជាណាចក្រកម្ពុជា រួមមាន ចៅក្រមអាសនៈ និងចៅក្រមអយ្យការ។

ចៅក្រមអាសនៈ និងចៅក្រមអយ្យការនៃតុលាការកំពូល សាលាឧទ្ធរណ៍ និង សាលាដំបូង ព្រមទាំងចៅក្រមទាំងអស់ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលកណ្ដាលរបស់ ក្រសួងយុត្តិធម៌ ។

## មាត្រា ២.-

អនុលោមតាមគោលការណ៍ជាសារវន្តទាក់ទងនឹងឯករាជភាពនៃអង្គចៅក្រម ដែល អនុម័តដោយអង្គការសហប្រជាជាតិ រដ្ឋនីមួយៗដែលជាសមាជិក មានកាតព្វកិច្ចផ្ដល់ ធនធានគ្រប់គ្រាន់ ដើម្បីឱ្យអង្គចៅក្រមអាចបំពេញមុខងាររបស់ខ្លួនបាន ។

## មាត្រា ៣.-

ចៅក្រមទាំងឡាយត្រូវសម្រេចសេចក្ដីដោយមិនលំអៀង ដោយឈរលើគោលការណ៍ គោរពច្បាប់ ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោល ពីភាគីណាមួយក្នុងរឿងក្ដី ឬពីអ្នកដទៃ ណាឡើយ ។

ចៅក្រមត្រូវបានធានាការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារ ក្នុងករណី ចាំបាច់ តាមសំណូមពររបស់សាមីខ្លួន ។

អង្គចៅក្រមមិនត្រូវចំណុះទៅនឹងអំណាចនីតិបញ្ញត្តិ ឬអំណាចនីតិប្រតិបត្តិ ឬ គណបក្សនយោបាយណាមួយឡើយ ។

ជនទាំងឡាយដែលត្រូវជ្រើសរើសសម្រាប់ឱ្យបំពេញមុខងារក្នុងអង្គចៅក្រម ត្រូវតែ ជាអ្នកមានសមត្ថភាព និងជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ ។

# ជំពូកទី ២
# ចៅក្រមអាសនៈ

**មាត្រា ៤.-**

ចៅក្រមអាសនៈ រួមមានចៅក្រមជម្រះក្តី និងចៅក្រមស៊ើបសួរ ។

ចៅក្រមអាសនៈ ត្រូវចាត់តាំងឱ្យបំពេញមុខងារនៅសាលាជម្រះក្តីណាមួយសម្រាប់រយៈពេល ៣ (បី) ឆ្នាំ ។

**មាត្រា ៥.-**

ចៅក្រមអាសនៈ មិនត្រូវបានផ្លាស់ប្តូរទៅកន្លែងណាមួយផ្សេងទៀត ដោយមិនមានការយល់ព្រមពីសាមីខ្លួនជាមុនឡើយ ក្នុងអំឡុងពេលបំពេញការងារដែលមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ ទោះជាកន្លែងនោះមានឋានន្តរស័ក្តិខ្ពស់ជាងក៏ដោយ លើកលែងតែចៅក្រមនោះមានទោសវិន័យថ្នាក់ទី ២ (ពីរ) ដូចមានចែងក្នុងមាត្រា ៥៨ នៃច្បាប់នេះ ។

**មាត្រា ៦.-**

ចៅក្រមអាសនៈ អាចត្រូវតែងតាំងជាចៅក្រមអយ្យការបាន ។

## ជំពូកទី ៣
## ចៅក្រមអយ្យការ

**មាត្រា ៧.-**

នៅអមសាលាជម្រះក្តីនីមួយៗនៃព្រះរាជាណាចក្រកម្ពុជា មានស្ថាប័នអយ្យការមួយដែលមានចៅក្រមអយ្យការ ជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ និងចោទប្រកាន់ជនប្រព្រឹត្តបទល្មើសជូនទៅតុលាការ ។

ចៅក្រមអយ្យការ ត្រូវបានចាត់តាំងឱ្យបំពេញមុខងារនៅអមសាលាជម្រះក្តីណាមួយសម្រាប់រយៈពេល ៣ (បី) ឆ្នាំ ។

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

ក្នុងរឿងរដ្ឋប្បវេណី ចៅក្រមអយ្យការត្រូវយកចិត្តទុកដាក់តាមដានក្នុងការគោរពច្បាប់និងបទបញ្ញា ដែលទាក់ទង ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍អសមត្ថជន និងតាមដានការអនុវត្តនូវសេចក្តីសម្រេចរបស់តុលាការ ។

**មាត្រា ៨.-**

គោលការណ៍សំខាន់ៗរបស់ចៅក្រមអយ្យការ ៖

១-ឯកភាពនៃអង្គការអយ្យការ តម្រូវឱ្យចៅក្រមអយ្យការទាំងអស់ត្រូវស្ថិតនៅក្រោមការណែនាំ និងត្រួតពិនិត្យរបស់ប្រធានតាមឋានានុក្រម ពោលគឺ ព្រះរាជអាជ្ញារងត្រូវធ្វើការក្រោមការបញ្ជាណែនាំ ដឹកនាំ និងទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា ។ ព្រះរាជ-អាជ្ញានៃអយ្យការអមសាលាដំបូងទាំងអស់ត្រូវទទួលខុសត្រូវ ចំពោះមុខអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្នុងករណីពិសេស រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានសិទ្ធិធ្វើអធិបញ្ញារទៅព្រះរាជអាជ្ញាអមសាលាដំបូង ។ ប៉ុន្តែនៅពេលសវនាការចៅក្រមអយ្យការមានសិទ្ធិបញ្ចេញមតិរបស់ខ្លួនដោយសេរី ទាក់ទងនឹងអង្គហេតុ និងអង្គច្បាប់នៃរឿង ។

២-គោលការណ៍ភាពចែកមិនដាច់ តម្រូវឱ្យចៅក្រមអយ្យការដែលបំពេញមុខងារនៅអមសាលាជម្រះក្តីណាមួយ ត្រូវមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នាជំនួសគ្នាទៅវិញទៅមកបាន ។ តាមគោលការណ៍នេះ សមាជិកពីរនាក់នៃស្ថាប័នអយ្យការ អាចឡើងបន្តការងារពីគ្នាបានក្នុងពេលជំនុំជម្រះរឿងក្តីមួយ ។

៣-ចៅក្រមអយ្យការ មិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តី ដែលខ្លួននៅអមនោះទេ ។

សាលាជម្រះក្តីនេះ គ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ចៅក្រមអយ្យការឡើយ ។

សាលាជម្រះក្តី ទោះបីក្នុងករណីដែលស្ថាប័នអយ្យការបានធ្វើការចោទប្រកាន់មិនត្រឹមត្រូវក៏ដោយ ក៏មិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួន យកការស្តីបន្ទោសអ្វីចំពោះចៅក្រមអយ្យការឡើយ ។ ការហាមឃាត់នេះ ត្រូវអនុវត្តក្នុងរឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណី ។ ប៉ុន្តែសាលាជម្រះក្តីអាចលើកសំណើទៅថ្នាក់លើរបស់ចៅក្រមអយ្យការអំពីអំពើខុសឆ្គងរបស់ចៅក្រមអយ្យការបាន ។

**មាត្រា ៩.-**

ជារៀងរាល់ឆ្នាំ ៖

- ព្រះរាជអាជ្ញាអមសាលាដំបូង ត្រូវធ្វើរបាយការណ៍អំពីបទល្មើស និងសកម្មភាពរបស់ខ្លួនជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើរបាយការណ៍ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អំពី

បទល្មើស សកម្មភាពរបស់ខ្លួន និងសកម្មភាពការងាររបស់អយ្យការអមសាលាដំបូងទូទាំងប្រទេស ។

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវធ្វើរបាយការណ៍ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងចម្លងជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អំពីសកម្មភាពរបស់អយ្យការអមតុលាការកំពូល ។

**មាត្រា ១០.-**

ចៅក្រមអយ្យការ អាចត្រូវតែងតាំងជាចៅក្រមអាសនៈបាន ។

## ជំពូកទី ៤
## ការចាត់តាំង ការផ្លាស់ប្តូរ ការផ្អាច់ពីមុខងារ ការដាក់ឱ្យនៅទំនេរ ការហូតងារ ការដាក់ឱ្យចូលនិវត្តន៍ និងការសុំលាឈប់

**មាត្រា ១១.-**

ចៅក្រមនៅសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែងតាំង ផ្លាស់ប្តូរ ផ្អាច់ពីមុខងារ ដាក់ឱ្យនៅទំនេរ ហូតងារ ការដាក់ឱ្យចូលនិវត្តន៍ និងការសុំលាឈប់ តាមសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអ្នកចាត់ចែងលើកសំណើ តាមការស្នើសុំរបស់សាម៉ីខ្លួន ឬរបស់អង្គភាពផ្សេងៗ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងសម្រេច ។

**មាត្រា ១២.-**

ក្នុងករណីចាំបាច់ ÷

- ចៅក្រមអាចត្រូវបានអនុញ្ញាតឱ្យផ្អាច់ពីមុខងារ ឬឱ្យដាក់នៅក្រៅក្របខ័ណ្ឌនៃអង្គចៅក្រមបាន តាមការស្នើសុំរបស់សាមីខ្លួន ឬស្ថាប័នផ្សេងៗ ដោយមានការយល់ព្រមពីសាមីខ្លួន និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ក្នុងរយៈពេលនៃការអនុញ្ញាតឱ្យផ្អាច់ពីមុខងារ ចៅក្រមនោះត្រូវបានបន្តទទួលប្រាក់បៀវត្ស ព្រមទាំងសិទ្ធិក្នុងការឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងសិទ្ធិក្នុងការចូលនិវត្តន៍របស់ខ្លួន ប៉ុន្តែពុំមានប្រាក់បំណាច់ និងប្រាក់រង្វាន់ផ្សេងៗទៀតនៃមុខងារដើមរបស់ខ្លួនទេ ។

- ចៅក្រមអាចត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្ន ក្នុងករណីដែលចៅក្រមនោះទទួលវិន័យ ឬត្រូវបានចោទប្រកាន់ដោយតុលាការ ។

- ចៅក្រមអាចត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌដើម ក្នុងការណីចៅក្រមនោះទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី ២ (ពីរ) ឬនៅពេលដែលចៅក្រមនោះបានបោះបង់ការងារ ឬអវត្តមានលើសពី ១ (មួយ) ខែ ដោយអនុវត្តតាមមាត្រា ៥៤ នៃច្បាប់នេះ ឬដោយសាមីខ្លួនសុំលាឈប់ជាស្ថាពរ ។

ការលាឈប់របស់ចៅក្រម ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន ។ ពាក្យសុំនេះ ត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលនឹងត្រូវបញ្ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និងសម្រេច ។

**មាត្រា ១៣.-**

ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវបានជ្រើសតាំង និងស្នើតែងតាំង ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមចៅក្រមដែលមានឋានន្តរស័ក្តិឧត្តមចៅក្រមថ្នាក់លេខ ១ (មួយ) ឡើងទៅ ។

ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញារង អមតុលាការកំពូល ត្រូវបានជ្រើសតាំង និងស្នើតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមឧត្តមចៅក្រមថ្នាក់លេខ ៣ (បី) ឡើងទៅ ។

អនុប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ត្រូវបានជ្រើសតាំង និងស្នើតែងតាំង ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមឧត្តម-ចៅក្រមថ្នាក់លេខ ៤ (បួន ) ឡើងទៅ ។

ចៅក្រមនៃតុលាការកំពូល ព្រះរាជអាជ្ញាអមតុលាការកំពូល ចៅក្រមនៃសាលា-ឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រធានតុលាការសាលាដំបូង និងព្រះរាជ-អាជ្ញាអមតុលាការសាលាដំបូង ត្រូវបានជ្រើសតាំង និងស្នើតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមចៅក្រមដែលមានឋានន្តរស័ក្តិវរៈចៅក្រមថ្នាក់លេខ ២ (ពីរ) ឡើងទៅ ។

អនុប្រធានតុលាការសាលាដំបូង និងព្រះរាជអាជ្ញារងអមតុលាការសាលាដំបូង ត្រូវបានជ្រើសតាំង និងស្នើតែងតាំង ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមចៅក្រម ដែលមានឋានន្តរស័ក្តិវរៈចៅក្រមឡើងទៅ ។

ចៅក្រមនៃតុលាការសាលាដំបូង ត្រូវបានជ្រើសតាំង និងស្នើតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមចៅក្រមដែលមានឋានន្តរស័ក្តិអនុចៅក្រមឡើងទៅ ។

ក្នុងករណីចាំបាច់ ចៅក្រមនៃសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ដែលពុំទាន់មានឋានន្តរស័ក្តិគ្រប់គ្រាន់ដូចមានចែងខាងលើ អាចត្រូវបានចាត់តាំងជាប្រធានស្តីទីបាន ក្នុងចំណោមចៅក្រមដែលមានអតីតភាពខ្ពស់ជាងគេ ។

## ជំពូកទី ៥
## ឋានន្តរស័ក្តិ និង ថ្នាក់

**មាត្រា ១៤.-**

ក្របខ័ណ្ឌចៅក្រមរួមមាន ៣ (បី) ឋានន្តរស័ក្តិ ÷

- ឧត្តមចៅក្រម
- វរៈចៅក្រម
- អនុចៅក្រម ។

**មាត្រា ១៥.-**

ឋានន្តរស័ក្តិឧត្តមចៅក្រមមាន ៤ (បួន) ថ្នាក់ ឋានន្តរស័ក្តិវរៈចៅក្រមមាន ៤ (បួន) ថ្នាក់ និងឋានន្តរស័ក្តិអនុចៅក្រមមាន ៦ (ប្រាំមួយ) ថ្នាក់ ។

## ជំពូកទី ៦
## ការជ្រើសរើស និងតែងតាំងក្នុងក្របខ័ណ្ឌចៅក្រម

**មាត្រា ១៦.-**

ត្រូវបានអនុញ្ញាតឱ្យប្រឡងជ្រើសរើសជាចៅក្រមកម្មសិក្សា ចំពោះបេក្ខជនជានិស្សិតដែលបានបំពេញ លក្ខខណ្ឌ ដូចខាងក្រោម ÷

១- ត្រូវមានសញ្ជាតិខ្មែរ

២- មានអាយុ ៣០ (សាមសិប) ឆ្នាំ យ៉ាងច្រើន គិតមកដល់ថ្ងៃប្រឡង

៣- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាបត្រច្បាប់ដ៏ទៃទៀតដែលមានតម្លៃសមមូល

៤- មិនដែលមានទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ

៥- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន ។

**មាត្រា ១៧.-**

ការប្រឡងជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌចៅក្រម អាចធ្វើតាមរយៈការប្រឡងប្រជែងផ្ទៃក្នុង ក្នុងចំណោមមន្ត្រីរាជការ ក្រឡាបញ្ជីដែលមានបរិញ្ញាប័ត្រច្បាប់ ហើយដែលមានអាយុមិនលើសពី ៤០ (សែសិប) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។

**មាត្រា ១៨.-**

ការកំណត់ចំនួននៃការជ្រើសរើសចៅក្រម ត្រូវធ្វើឡើងតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ១៩.-**

ត្រូវបានអនុញ្ញាតឱ្យប្រឡងចូលក្នុងក្របខ័ណ្ឌចៅក្រមផងដែរ ចំពោះ÷

- បេក្ខជនដែលមានសញ្ញាបត្របណ្ឌិតច្បាប់
- បេក្ខជនជាស្ត្រីដែលមានបរិញ្ញាប័ត្រច្បាប់ ហើយបានចិញ្ចឹមកូនអាយុក្រោម ៥ (ប្រាំ) ឆ្នាំ យ៉ាងតិច ២ (ពីរ) នាក់
- មានអាយុយ៉ាងច្រើន ៣៥ (សាមសិប) ឆ្នាំ ។

**មាត្រា ២០.-**

បេក្ខជនដែលប្រឡងជាប់ចូលក្នុងក្របខ័ណ្ឌចៅក្រម ត្រូវតែងតាំងជាអនុចៅក្រមកម្មសិក្សាថ្នាក់ទី ៦ (ប្រាំមួយ) ។

បេក្ខជនដែលបានប្រឡងជាប់ក្នុងចំណោមមន្ត្រីរាជការ មកពីខាងក្រៅ និងផ្ទៃក្នុង ត្រូវរក្សាទុកអតីតភាពការងារ ។

**មាត្រា ២១.-**

ទម្រង់ និងបែបបទនៃការប្រឡងប្រជែងជ្រើសរើសចៅក្រម ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

**មាត្រា ២២.-**

ការរៀបចំប្រឡងប្រជែង ត្រូវធ្វើដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដែលត្រូវកំណត់ក្រោយពីបានពិគ្រោះយោបល់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ÷

- ចំនួនកន្លែងដែលដាក់ឱ្យប្រឡងប្រជែង
- មណ្ឌល កាលបរិច្ឆេទ និងពេលវេលាដែលត្រូវចាប់ផ្ដើម
- សមាសភាពគណៈមេប្រយោគ ។

**មាត្រា ២៣.-**

កាលបរិច្ឆេទប្រឡងប្រជែងត្រូវរៀបចំឡើង ៤៥ (សែសិបប្រាំ) ថ្ងៃ យ៉ាងតិច ក្រោយពីការប្រកាសផ្សាយជាសាធារណៈ ។

ការប្រកាសផ្សាយនេះ ត្រូវធ្វើតាមគ្រប់មធ្យោបាយ ដើម្បីអោយបេក្ខជនទាំងឡាយបានដឹង ។

## ជំពូកទី ៧
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ និងការលុបឈ្មោះចេញពីក្របខ័ណ្ឌចៅក្រម

### មាត្រា ២៤.-

ចៅក្រមដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង ក្នុងចំណោមនិស្សិត និងមន្ត្រីរាជការ ត្រូវធ្វើកម្មសិក្សារយៈពេល ១ (មួយ) ឆ្នាំ ។ រយៈពេលកម្មសិក្សាត្រូវគិតពីថ្ងៃតែងតាំងជាកម្មសិក្សាការី ។

### មាត្រា ២៥.-

ក្រោយពីបានបំពេញកម្មសិក្សា ចៅក្រមកម្មសិក្សាត្រូវបានតែងតាំងជាអនុចៅក្រមពេញសិទ្ធិថ្នាក់ទី ៦ (ប្រាំមួយ) ។ ចំពោះចៅក្រមកម្មសិក្សា ដែលមានសញ្ញាបត្របណ្ឌិតឡើងទៅ ត្រូវបានតែងតាំងជាអនុចៅក្រមពេញសិទ្ធិថ្នាក់ទី ៤ (បួន) ។

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌចៅក្រម ត្រូវមានការសម្រេចយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចសម្រេចឱ្យបន្តធ្វើកម្មសិក្សា ១ (មួយ) ឆ្នាំបន្ថែមទៀត ចំពោះចៅក្រមកម្មសិក្សា កាលបើមានមូលហេតុច្បាស់លាស់ថា ចៅក្រមកម្មសិក្សានោះពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សា ឬមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី ៣០ (សាមសិប) ថ្ងៃ ។ ក្នុងករណីដែលចៅក្រមកម្មសិក្សាឈប់រហូតលើសពី ៣០ (សាមសិប) ថ្ងៃ ដោយគ្មានការអនុញ្ញាតច្បាប់ ត្រូវលុបឈ្មោះចេញពីបញ្ជី ជាស្វ័យប្រវត្តិ ។

ចៅក្រមកម្មសិក្សា ដែលមិនបានទទួលជោគជ័យជាថ្មីម្តងទៀតក្នុងការធ្វើកម្មសិក្សាបន្ថែម នឹងត្រូវលុបឈ្មោះចេញ ។

### មាត្រា ២៦.-

កម្មសិក្សាការីដែលមិនបានបង្ហាញសម្បទាគ្រប់គ្រាន់ ឬមានសុខភាពមិនគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌ ដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងក្នុង

ការបម្រើការងារមិនបានពេញលេញ អាចត្រូវលុបឈ្មោះចេញពីបញ្ជីចៅក្រមកម្មសិក្សា បានគ្រប់ពេលវេលា ក្រោយពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ការលុបឈ្មោះចេញ ឬការតាំងស៊ប់ក្នុងក្របខ័ណ្ឌចៅក្រម ត្រូវសម្រេចក្នុងរយៈពេល ៣ (បី) ខែ យ៉ាងយូរ ក្រោយពីបានបញ្ចប់កម្មសិក្សា ។ ការតាំងស៊ប់ក្នុងក្របខ័ណ្ឌចៅក្រម មានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងអតីតភាពចាប់ពីថ្ងៃផុតកំណត់កម្មសិក្សា ។

**មាត្រា ២៧.-**

ចៅក្រមទាំងឡាយ ដែលពុំមានលទ្ធភាពបន្តមុខងាររបស់ខ្លួន ដោយហេតុមកពីបញ្ញាសម្បទា ឬកាយសម្បទាមិនគ្រប់គ្រាន់ ហើយដែលបំពេញមិនបាននូវលក្ខខណ្ឌដើម្បីទទួលប្រាក់សោធននិវត្តន៍ អាចត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌចៅក្រមបានគ្រប់ពេលវេលា ដោយមិនគិតដល់បទប្បញ្ញត្តិនៃមាត្រា ៨៩ នៃច្បាប់នេះ ។

ការសម្រេចអំពីការបាត់បង់បញ្ញាសម្បទា ឬកាយសម្បទា ត្រូវធ្វើដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយសំអាងលើលិខិតកោសល្យវិច័យពេទ្យជំនាញដែលស្ថាប័នមានសមត្ថកិច្ចបានចាត់តាំង និងបានស្បថរួចហើយ ។

ចៅក្រមដែលត្រូវលុបឈ្មោះចេញដោយមូលហេតុបញ្ញាសម្បទា ឬកាយសម្បទាមិនគ្រប់គ្រាន់ ហើយដែលគ្មានលក្ខណៈគ្រប់គ្រាន់នឹងទទួលប្រាក់សោធននិវត្តន៍ និងដោយមូលហេតុផ្សេងទៀត ក្រៅពីទណ្ឌកម្មវិន័យ មានសិទ្ធិជ្រើសរើសយកប្រាក់ឧបត្ថម្ភស្មើនឹងប្រាក់បៀវត្សសុទ្ធសាធរបស់ខ្លួនបូកនឹងប្រាក់ជីវភាពគ្រួសារផងចំនួន ១ (មួយ) ខែ កាលបើបានបម្រើការងាររយៈពេល ១២ (ដប់ពីរ) ខែ ឬជ្រើសរើសយកប្រាក់ដែលបានកាត់ទុកដោយបេឡាសោធននិវត្តន៍ ។

## ជំពូកទី ៨
## អំពីវិសមិតភាព

**មាត្រា ២៨.-**

ចៅក្រមមិនអាចចូលរួមជំនុំជម្រះនូវរឿងក្តីតែមួយជាមួយសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ទោះក្នុងឋានៈជាចៅក្រមអាសនៈក្តី ចៅក្រមអយ្យការក្តី ឬក៏ម្នាក់ជំនុំជម្រះនៅសាលាឧទ្ធរណ៍ ឬ

នៅតុលាការកំពូល នូវរឿងក្តីដែលម្នាក់ទៀតបានជំនុំជម្រះនៅសាលាដំបូង ឬនៅសាលា-ឧទ្ធរណ៍បានឡើយ បើពុំដូច្នោះទេ សាលាក្រម ឬសាលដីកានោះ ត្រូវទុកជាមោឃៈ ។

**មាត្រា ២៩.-**

ចៅក្រមមិនអាចចូលរួមជំនុំជម្រះនូវរឿងក្តីតែមួយដែលសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ធ្វើជាមេធាវីឱ្យភាគីណាមួយក្នុងរឿងក្តីណាមួយបានឡើយ បើពុំដូច្នោះទេ សាលក្រម ឬសាលដីកានោះ ត្រូវទុកជាមោឃៈ ។

**មាត្រា ៣០.-**

ចៅក្រមដែលបានទទួលធ្វើអន្តរាគមន៍ក្នុងឋានៈជាអាជ្ញាកណ្តាល ក្នុងវិវាទពាណិជ្ជ-កម្មណាមួយ មិនអាចជំនុំជម្រះរឿងដដែលនោះនៅគ្រប់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ បានឡើយ ។

ចៅក្រមក៏មានវិសមិតភាពផងដែរ ក្នុងការតាក់តែងរៀបរៀងលិខិតលក្ខន្តិកៈ និងកិច្ចសន្យាផ្សេងៗផ្នែកពាណិជ្ជកម្ម ។

**មាត្រា ៣១.-**

ការប្រកបមុខងារជាចៅក្រម មានវិសមិតភាពជាមួយមុខងារសាធារណៈ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ។

មុខងារជាចៅក្រមក៏មានវិសមិតភាពផងដែរ ជាមួយមុខរបរពាណិជ្ជកម្ម ឬការប្រកបរបរណាមួយផ្សេងទៀត ដែលប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម ។

**មាត្រា ៣២.-**

ចៅក្រមដែលបានអនុញ្ញាតឱ្យនៅទំនេរ ប្រសិនបើមានបំណងប្រកបការងារឯកជន ត្រូវជូនដំណឹងដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជំទាស់មិនឱ្យប្រកបការងារនោះបាន ប្រសិនបើយល់ឃើញថា សកម្មភាពទាំងនោះផ្ទុយនឹងកិត្តិយស ឬសេចក្តីទៀងត្រង់ ឬខ្ទចកិត្យានុភាពនៃមុខងារចៅក្រម ។

ក្នុងករណីដែលមានការរំលោភលើមាត្រានេះ ចៅក្រមដែលដាក់ឱ្យនៅទំនេរ ត្រូវទទួលទោសជាវិន័យ ដូចមានចែងក្នុងមាត្រា ៥៨ នៃច្បាប់នេះ ។

# ជំពូកទី ៩
# ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិ

## មាត្រា ៣៣.-

ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាព ស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ ។

លក្ខខណ្ឌនៃការតម្លើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមវេនអតីតភាព ត្រូវគិតក្នុងសមាមាត្រមិនឱ្យលើសពី ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

## មាត្រា ៣៤.-

ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិរបស់ចៅក្រមត្រូវផ្អែកលើមូលដ្ឋាន÷

- គោរពវិន័យការងារបានត្រឹមត្រូវ
- សម្រេចភារកិច្ចបានល្អ
- មានកិរិយាមាយាទ និងសីលធម៌ល្អ មិនធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ឆ្លងកាត់វគ្គបណ្តុះបណ្តាលនានានៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានានា
- ធ្វើការនៅតំបន់ដាច់ស្រយាល តំបន់ប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ ។

ក្នុងរយៈពេលនៃការបំពេញការងារ ចៅក្រមដែលបានខិតខំសិក្សាបន្ថែម ហើយបានទទួលសញ្ញាបត្រក្រោយឧត្តមសិក្សា ត្រូវបានលើកទឹកចិត្តដោយធ្វើការតម្លើងថ្នាក់បន្ថែម ១ (មួយ) ថ្នាក់ទៀត ។

## មាត្រា ៣៥.-

សម្រាប់ថ្នាក់ និងឋានន្តរស័ក្តិនីមួយៗនៃឋានានុក្រម ចំនួនចៅក្រមដែលគ្រោងឱ្យឡើងថ្នាក់ ឬឋានន្តរស័ក្តិសម្រាប់ឆ្នាំនីមួយៗ នឹងត្រូវកំណត់ទៅតាមតម្រូវការនៃការងារ និងទៅតាមគំរោងថវិកាជាតិ ។

## មាត្រា ៣៦.-

ចៅក្រមក្នុងឋានន្តរស័ក្តិតែមួយ អាចឡើងថ្នាក់បានម្តងមួយថ្នាក់ ។ ក្នុងករណីដែលត្រូវប្តូរឋានន្តរស័ក្តិ ត្រូវឡើងថ្នាក់ក្រោមបំផុតនៃឋានន្តរស័ក្តិខ្ពស់ជាងនេះ ។

ក្នុងករណីចាំបាច់ ចៅក្រមអាចប្តូរឋានន្តរស័ក្តិបាន តាមរយៈការប្រឡង ។

**មាត្រា ៣៧.-**

ត្រូវបានតម្លើងឋានន្តរស័ក្តិជាឧត្តមចៅក្រម ចំពោះវរៈចៅក្រមទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១ (មួយ) នៃឋានន្តរស័ក្តិ ។

ត្រូវបានតម្លើងឋានន្តរស័ក្តិជាវរៈចៅក្រម ចំពោះអនុចៅក្រមទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១ (មួយ) នៃឋានន្តរស័ក្តិ ។

ការតម្លើងឋានន្តរស័ក្តិដល់ចៅក្រម ត្រូវផ្អែកតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៣ និងមាត្រា ៣៤ ឬតាមការប្រឡងប្រជែងដែលកំណត់ដោយប្រកាសរបស់ ក្រសួងយុត្តិធម៌ តាមតម្រូវកានៃការងារក្រោយពីបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃ អង្គចៅក្រម ។

**មាត្រា ៣៨.-**

ជារៀងរាល់ឆ្នាំនៅខែមករា ចៅក្រមម្នាក់ៗត្រូវបានទទួលពីក្រសួងយុត្តិធម៌ នូវព្រឹត្តិប័ត្រឯកត្តជន ដែលចៅក្រមនោះត្រូវបំពេញតាមចំណុចសំណួរទាំងឡាយ ។

ប្រធានផ្ទាល់នៃចៅក្រមសាមី ត្រូវដាក់ពិន្ទុលើព្រឹត្តិប័ត្រទាំងនោះ ដោយបញ្ជាក់យោបល់ និងមូលហេតុច្បាស់លាស់ ។

១-អនុប្រធានតុលាការ និងចៅក្រមនៃសាលាដំបូង ត្រូវប្រធានជាអ្នកដាក់ពិន្ទុ ។ ព្រះរាជអាជ្ញារងអមសាលាដំបូង ត្រូវព្រះរាជអាជ្ញាជាអ្នកដាក់ពិន្ទុក ។

២-ប្រធានសាលាដំបូង ចៅក្រមសាលាឧទ្ធរណ៍ និងអនុប្រធានសាលាឧទ្ធរណ៍ ត្រូវប្រធានសាលាឧទ្ធរណ៍ជាអ្នកដាក់ពិន្ទុ ។ ព្រះរាជអាជ្ញាអមសាលាដំបូង ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣-អនុប្រធានតុលាការកំពូល ចៅក្រមនៃតុលាការកំពូល និងប្រធានសាលា-ឧទ្ធរណ៍ ត្រូវប្រធានតុលាការកំពូលជាអ្នកដាក់ពិន្ទុ ។ អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ព្រះរាជអាជ្ញាអមតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវអគ្គព្រះរាជអាជ្ញានៃតុលាការកំពូលជាអ្នកដាក់ពិន្ទុ ។

៤-ចៅក្រមដែលបានផ្លាស់ឱ្យទៅបំពេញភារកិច្ចនៅស្ថាប័នផ្សេងៗ ត្រូវប្រធានស្ថាប័នសាមីជាអ្នកដាក់ពិន្ទុ ។

**មាត្រា ៣៩.-**

អាចឱ្យចុះឈ្មោះក្នុងតារាងតម្លើងថ្នាក់បាន ចំពោះតែចៅក្រមណាដែលបានបម្រើការងារក្នុងឋានន្តរស័ក្តិ ឬថ្នាក់របស់ខ្លួនយ៉ាងតិច ២ (ពីរ) ឆ្នាំ គិតមកទល់ថ្ងៃ ១៣ ខែមេសា នៃឆ្នាំនីមួយៗ ។

**មាត្រា ៤០.-**

សមាសភាពនៃគណៈកម្មការតម្លើងថ្នាក់ និងឋានន្តរស័ក្តិរួមមាន÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| - ប្រធានតុលាការកំពូល | អនុប្រធាន |
| - អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | អនុប្រធាន |
| - ប្រធានសាលាឧទ្ធរណ៍ | សមាជិក |
| - អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | សមាជិក |
| - អគ្គាធិការកិច្ចការតុលាការ | សមាជិក |
| - ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងយុត្តិធម៌ | លេខាធិការ ។ |

**មាត្រា ៤១.-**

តារាងបេក្ខជនដែលបានស្នើតម្លើងថ្នាក់សម្រាប់ឋានន្តរស័ក្តិនីមួយៗ ត្រូវរៀបចំតាមលំដាប់អតីតភាពស្របតាមតារាងនៃថ្នាក់នីមួយៗ ក្រោមការចាត់ចែងរបស់ក្រសួងយុត្តិធម៌ ។

**មាត្រា ៤២.-**

តារាងនេះ ត្រូវបិទផ្សាយឱ្យសាមីជនដឹងនៅគ្រប់សាលាជំនុំជម្រះក្តី ។

**មាត្រា ៤៣.-**

ចៅក្រមណាមួយដែលមានអតីតភាពគ្រប់កំណត់ ត្រូវស្នើតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ ហើយគ្មានឈ្មោះក្នុងតារាងខាងលើនេះ ចៅក្រមនោះអាចប្តឹងតវ៉ាសុំចុះឈ្មោះរបស់ខ្លួនទៅក្រសួងយុត្តិធម៌ ក្នុងរយៈពេល ៣០ (សាបសិប) ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃទទួលដំណឹងអំពីតារាងស្នើតម្លើងថ្នាក់ និងឋានន្តរស័ក្តិ ។ ផុតរយៈពេលនេះ បណ្តឹងតវ៉ាត្រូវទុកជាអសារបង់ ។

**មាត្រា ៤៤.-**

ក្រសួងយុត្តិធម៌ ត្រូវបញ្ជូនព្រឹត្តិប័ត្រឯកត្តជនរបស់ចៅក្រម ចុះក្នុងបញ្ជីនៃថ្នាក់នីមួយៗ និងព្រឹត្តិប័ត្រឯកត្តជនរបស់ចៅក្រមដែលបានប្ដឹងតវ៉ាទៅគណៈកម្មការតម្លើងថ្នាក់ និងឋានន្តរស័ក្តិដែលមានចែងក្នុងមាត្រា ៤០ ឱ្យបានក្នុងសប្ដាហ៍ទី ១ ខែ មីនា នៃឆ្នាំនីមួយៗ ។

**មាត្រា ៤៥.-**

ប្រធានគណៈកម្មការតម្លើងថ្នាក់ និងឋានន្តរស័ក្តិ ជាអ្នកកោះអញ្ជើញគណៈកម្មការខាងលើប្រជុំ ។

**មាត្រា ៤៦.-**

គណៈកម្មការនេះ ត្រូវរួមប្រជុំឱ្យបានមុនថ្ងៃចូលឆ្នាំថ្មីប្រពៃណីខ្មែរ ។

**មាត្រា ៤៧.-**

ក្រោយពីបានពិនិត្យព្រឹត្តប័ត្រឯកត្តជន និងសម្រេចលើបណ្ដឹងតវ៉ា និងក្រោយពីបានស្ដាប់សេចក្ដីពន្យល់សព្វគ្រប់របស់ប្រធាន សមាជិកម្នាក់ៗត្រូវដាក់ពិន្ទុពី ០ (សូន្យ) ដល់ ២០ (ម្ភៃ) ដល់ចៅក្រមបេក្ខជនម្នាក់ៗ ។ ការចុះឈ្មោះក្នុងតារាងបេក្ខជន ត្រូវធ្វើតាមលំដាប់គុណសម្បត្តិនៃលទ្ធផលពិន្ទុសរុប ។ ប្រសិនបើមានបេក្ខជនពីរនាក់ទទួលពិន្ទុស្មើគ្នា នោះបេក្ខជនដែលមានអាយុច្រើនជាង ត្រូវចុះឈ្មោះមុនគេក្នុងបញ្ជី ។

**មាត្រា ៤៨.-**

គណៈកម្មការតម្លើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវរៀបចំតារាងទៅតាមជំនាន់ចៅក្រមដែលតម្លើងថ្នាក់ និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់ក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងសម្រេច ។ សេចក្ដីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ។

សេចក្ដីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបញ្ជូនមកក្រសួងយុត្តិធម៌ ដើម្បីរៀបចំព្រះរាជក្រឹត្យដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្ថលេខា ។

**មាត្រា ៤៩.-**

ចៅក្រមណាដែលកំពុងជាប់ក្នុងការអង្កេតជាបទវិន័យ ឬបទល្មើសព្រហ្មទណ្ឌ ត្រូវផ្អាកមិនទាន់ឱ្យមានសិទ្ធិចុះឈ្មោះក្នុងតារាងតម្លើងថ្នាក់ ឬឋានន្តរស័ក្តិទេ ។

**មាត្រា ៥០.-**

ក្នុងករណីដែលបេក្ខជនមិនត្រូវបានតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ បេក្ខជននោះមានអាទិភាពត្រូវបានចុះឈ្មោះមុនគេ ក្នុងតារាងតម្លើងថ្នាក់ ឬឋានន្តរស័ក្តិនៅឆ្នាំបន្ទាប់ ។

**មាត្រា ៥១.-**

ការតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ និងការតម្លើងប្រាក់បៀវត្ស និងអតីតភាពត្រូវគិតចាប់ពីថ្ងៃទី ១៣ ខែមេសា នៃឆ្នាំនីមួយៗ ។

## ជំពូកទី ១០
## អំពីទោសវិន័យ និងករណីល្មើសនឹងបទព្រហ្មទណ្ឌ
### ផ្នែកទី ១
### ភារកិច្ចចៅក្រម

**មាត្រា ៥២.-**

ចៅក្រម ត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ ។

ក្នុងជីវភាពរស់នៅផ្ទាល់ខ្លួន ចៅក្រមមិនត្រូវប្រព្រឹត្តអំពើណាមួយ ដែលនាំឱ្យអាប់ឱនដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គចៅក្រមឡើយ ។

ក្នុងវិស័យនយោបាយ ចៅក្រមត្រូវប្រកាន់ដាច់ខាតនូវឥរិយាបថអព្យាក្រិត្យ ។

**មាត្រា ៥៣.-**

ចៅក្រមទាំងអស់ មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ ។

**មាត្រា ៥៤.-**

ការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ដោយពុំមានមូលហេតុចាប់ពី ១៥ (ដប់ប្រាំ) ថ្ងៃ ឡើងទៅ ត្រូវទទួលវិន័យផ្អាកមិនឱ្យបើកប្រាក់បៀវត្ស ឬដាក់ឱ្យនៅទំនេរគ្មានបៀវត្សដោយគិតពីថ្ងៃបោះបង់ការងារ ឬថ្ងៃអវត្តមានគ្មានការអនុញ្ញាតនោះ ។ បើបោះបង់ការងារ ឬអវត្តមានឥតច្បាប់ដោយពុំមានមូលហេតុលើសពី ១ (មួយ) ខែ ហើយចៅក្រមនោះនៅតែមិនត្រឡប់មកបំពេញការងារវិញ ក្រោយការដាក់កំហិតពីរដងនោះ ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ ។

**មាត្រា ៥៥.-**

ចៅក្រមដែលកំពុងបំពេញមុខងារ នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវសុំការអនុញ្ញាតជាមុនពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមុននឹងផ្សាយ ឬសុំឱ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណៅ ព្រមទាំងមតិផ្សេងៗដែលទាក់ទងនឹងមុខងាររបស់ខ្លួន ។

ការរំលោភលើបញ្ញត្តិនៃមាត្រានេះ ត្រូវទទួលទោសវិន័យ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទព្រហ្មទណ្ឌប្រសិនបើមាន ។

**មាត្រា ៥៦.-**

ចៅក្រមអាចបំពេញមុខងារជាសាស្ត្រាចារ្យនៅគ្រប់គ្រឹះស្ថានសិក្សា ។

## ផ្នែកទី ២
## អំពីទណ្ឌកម្មខាងវិន័យ និងនីតិវិធី

**មាត្រា ៥៧.-**

ការខ្វះខាតរបស់ចៅក្រមក្នុងការបំពេញវិជ្ជាជីវៈ ការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរ ប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជ-អាជ្ញា ត្រូវចាត់ទុកជាកំហុសខាងវិន័យ ។ កំហុសនេះត្រូវទទួលទណ្ឌកម្មខាងវិន័យ តាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ទណ្ឌកម្មខាងវិន័យក្នុងកថាខណ្ឌខាងលើនេះ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើនមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

ការមិនអាចបំពេញការងារបានពេញលេញក្នុងវិជ្ជាជីវៈ ដោយមូលហេតុកាយសម្បទា ឬបញ្ញាសម្បទាចុះខ្សោយ ត្រូវដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ ឬបញ្ឈប់ពីការងារ ។

ក្នុងករណីបញ្ឈប់ពីការងារ សាមីខ្លួនអាចទទួលយកប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬបទបញ្ជានៃបេឡាសោធននិវត្តន៍ ។

**មាត្រា ៥៨.-**

ទណ្ឌកម្មខាងវិន័យមាន ២ (ពីរ) ថ្នាក់គឺ ÷

១- ទណ្ឌកម្មថ្នាក់ទី ១ (មួយ)

ក- ស្តីបន្ទោសដោយផ្ទាល់មាត់ ។

ខ-ស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន ។

គ-ផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងតម្លើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈ តែមិនត្រូវឱ្យលើសពី ២ (ពីរ) ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងតម្លើងថ្នាក់ ឬ ឋានន្តរស័ក្តិវិញ ក្នុងករណីដែលមានចុះឈ្មោះរួចហើយ ។

២- ទណ្ឌកម្មថ្នាក់ទី ២ (ពីរ)

ក-ផ្លាស់ដោយបង្ខំ ។

ខ- ព្យួរពីការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេលមិនឱ្យលើសពី ១ (មួយ) ឆ្នាំ ។

គ- បន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ ។

ឃ-ដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់ ។

ង- បណ្តេញចេញពីក្របខ័ណ្ឌ ។

## មាត្រា ៥៩.-

ក្នុងករណីមានកំហុសមិនធ្ងន់ធ្ងរ បណ្តាលមកពីការធ្វេសប្រហែស ឬការមិនយកចិត្តទុកដាក់ក្នុងការងារ ហើយប្រធានផ្ទាល់បានស្តីបន្ទោសពីរដងក្នុងរឿងដដែល នៅតែពុំកែប្រែ នោះប្រធានផ្ទាល់ត្រូវរាយការណ៍ជូនទៅប្រធានក្រុមប្រឹក្សាវិន័យ ដោយយោងទៅតាមករណីសាមីខ្លួនជាចៅក្រមអាសនៈ ឬជាចៅក្រមអយ្យការ ។

## មាត្រា ៦០.-

រាល់ពាក្យបណ្តឹងត៍វ៉ា ពីរូបវ័ន្តបុគ្គល ឬនីតិបុគ្គល ពាក់ព័ន្ធដល់វិន័យ ចៅក្រម-អាសនៈ ឬចៅក្រមអយ្យការ ដែលកើតឡើងនៅតាមសាលាជំរះក្តី និងស្ថាប័នអយ្យការគ្រប់ជាន់ថ្នាក់ អគ្គាធិការដ្ឋានកិច្ចការតុលាការត្រូវចុះធ្វើអធិការកិច្ច រួចធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ និងបញ្ជូនទៅប្រធានក្រុមប្រឹក្សាវិន័យ ដោយយោងទៅតាមករណី ។

ក្នុងករណីដែលមានកំហុសធ្ងន់ធ្ងរ និងបន្ទាន់ក្នុងការងារ ប្រធានផ្ទាល់ត្រូវរាយការណ៍ជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីចាត់វិធានការណ៍សមស្រប ។

## មាត្រា ៦១.-

ការស៊ើបអង្កេតពីបទវិន័យ ត្រូវប្រគល់ជូនចៅក្រមដែលមានឋានន្តរស័ក្តិខ្ពស់ជាងចៅក្រមមានរឿង តាមសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាវិន័យ ដោយយោងទៅតាមករណី ។

ចៅក្រមដែលត្រូវទទួលភារៈស៊ើបអង្កេត ជាចៅក្រមដែលមិនបម្រើការងារនៅតុលាការដែលមានការពាក់ព័ន្ធ ។

## មាត្រា ៦២.-

ក្រោយពីបានធ្វើការអង្កេតស៊ើបសួរ និងប្រមូលភស្តុតាងគ្រប់គ្រាន់រួចហើយ ចៅក្រមដែលបានចាត់តាំងឱ្យធ្វើការអង្កេតនោះ ត្រូវឱ្យដំណឹងទៅចៅក្រមដែលមានកំហុស ។ ចៅក្រមនេះអាចសុំពិនិត្យសំណុំរឿងចោទប្រកាន់ និងសំណុំរឿងផ្ទាល់ខ្លួន និងជូនចម្លើយការពារខ្លួន ព្រមទាំងធ្វើការកត់សំគាល់ផ្សេងៗជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់ជាមួយនូវបញ្ជីរាយឈ្មោះសាក្សី និងឯកសារដែលខ្លួនសំអាង ព្រមទាំងឈ្មោះមេធាវីដើម្បីការពារខ្លួន ប្រសិនបើមាន ។

## មាត្រា ៦៣.-

ចៅក្រមទទួលភារៈស៊ើបអង្កេត បើយល់ឃើញថា ត្រូវធ្វើការស៊ើបអង្កេតបន្ថែមអាចអញ្ជើញចៅក្រម ដែលមានកំហុសនោះមកបំភ្លឺបន្ថែម ។ ចៅក្រមទទួលភារៈស៊ើបអង្កេតមានកាតព្វកិច្ចត្រូវធ្វើអង្កេតឱ្យបានច្បាស់លាស់ និងពេញលេញ លើកំហុសដែលត្រូវបានចោទប្រកាន់នោះ ។

ក្នុងករណីចាំបាច់ ចៅក្រមទទួលភារៈស៊ើបអង្កេត អាចចុះធ្វើការស៊ើបអង្កេតផ្ទាល់ដល់ទីកន្លែងនៃរឿងដែលកើតឡើងដោយមានលេខាធិការម្នាក់ ឬច្រើននាក់ជាជំនួយការ ហើយថវិកានៃការស៊ើបអង្កេតជាបន្ទុករបស់ក្រសួងយុត្តិធម៌ ។

## មាត្រា ៦៤.-

ក្រោយពីបានបំពេញទម្រង់ខាងលើនេះរួចហើយ ចៅក្រមទទួលភារៈស៊ើបអង្កេតត្រូវធ្វើរបាយការណ៍អធិប្បាយមួយចំណែកពីរឿងហេតុដែលបានចោទប្រកាន់ ហើយមួយចំណែកទៀតពីភស្តុតាងដាក់បន្ទុកដែលបានរកឃើញ ប៉ុន្តែក៏ត្រូវលើកឡើងពីភស្តុតាងដោះបន្ទុកដែរ ។

ចៅក្រមទទួលភារៈស៊ើបអង្កេត អាចលើកយោបល់របស់ខ្លួនជូនសម័យប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបាន ។

**មាត្រា ៦៥.-**

ចៅក្រមដែលមានរឿង និងមេធាវីរបស់ខ្លួនប្រសិនបើមាន ត្រូវបានកោះអញ្ជើញ និងជូនដំណឹងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃប្រជុំក្រុមប្រឹក្សាវិន័យ ។

**មាត្រា ៦៦.-**

ការមិនគោរពនីតិវិធីដែលមានចែងក្នុងមាត្រា ៦១ មាត្រា ៦២ និងមាត្រា ៦៥ ត្រូវទុកជាមោឃៈ ។

**មាត្រា ៦៧.-**

នៅពេលបើកការពិភាក្សា និងក្រោយពីបានស្តាប់ការអធិប្បាយរបស់ចៅក្រមរបាយការណ៍ អំពីនីតិវិធីនៃការស៊ើបអង្កេត ក្រុមប្រឹក្សាវិន័យត្រូវពិនិត្យអំពីករណីដែលនាំឱ្យមោឃភាពខាងលើ ដោយសុំឱ្យសមាជិកនៃក្រុមប្រឹក្សាវិន័យ ជូនយោបល់របស់ខ្លួនម្នាក់ម្តងៗ ។

ក្រោយពីប្រធានក្រុមប្រឹក្សាវិន័យប្រកាសថា នីតិវិធីនេះត្រឹមត្រូវហើយ ប្រធានក្រុមប្រឹក្សាវិន័យត្រូវឱ្យចៅក្រមរបាយការណ៍ រាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន ។

បន្ទាប់មក ប្រធានក្រុមប្រឹក្សាវិន័យអញ្ជើញចៅក្រមមានរឿងឱ្យធ្វើការដោះសារតាមការដែលគេយល់ឃើញថា មានប្រយោជន៍សម្រាប់ការពារខ្លួនគេ ។ សាមីខ្លួនអាចធ្វើសំណូមពរសុំឱ្យមេធាវីធ្វើការដោះសារជំនួសខ្លួនបាន ។

សមាជិកនៃក្រុមប្រឹក្សាវិន័យ អាចដាក់សំណួរទៅចៅក្រមដែលមានរឿងបាន កាលបើខ្លួនយល់ឃើញថា មានប្រយោជន៍ក្នុងរឿងនេះ ប៉ុន្តែមិនត្រូវលាតសន្ធឹងទៅលើករណីផ្សេងទៀតទេ ។

**មាត្រា ៦៨.-**

នៅពេលដែលសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ ហើយក្រោយពីចៅក្រមដែលមានរឿង ឬមេធាវីរបស់ចៅក្រមនោះមានមតិចុងក្រោយ ក្រុមប្រឹក្សាវិន័យត្រូវធ្វើការពិភាក្សាសម្រេចដោយសម្ងាត់ និងដោយគ្មានវត្តមាននៃចៅក្រមដែលមានរឿង និងមេធាវី ។

**មាត្រា ៦៩.-**

ការពិភាក្សាសម្រេច ត្រូវធ្វើជាសម្ងាត់ ដោយផ្តោតតែទៅលើកំហុសដែលត្រូវបានចោទប្រកាន់ ។ ក្នុងករណីមានកំហុស ក្រុមប្រឹក្សាវិន័យត្រូវបោះឆ្នោតជាសម្ងាត់ ជ្រើសរើសទណ្ឌកម្មថ្នាក់ទី ១ (មួយ) ឬទី ២ (ពីរ) ដូចមានកំណត់ក្នុងមាត្រា ៥៨ ។ បន្ទាប់មកត្រូវធ្វើការបោះឆ្នោតជ្រើសរើសទណ្ឌកម្មណាមួយនៃថ្នាក់នោះ ដែលត្រូវដាក់ទៅលើចៅក្រមសាមី ។ ក្នុងករណីខ្លះ ក្រុមប្រឹក្សាវិន័យអាចសម្រេចដាក់ទណ្ឌកម្មពីរដែលស្ថិតក្នុងថ្នាក់ជាមួយគ្នាបាន ។

**មាត្រា ៧០.-**

សំណុំរឿងស៊ើបអង្កេតព្រមទាំងរបាយការណ៍ និងសំណុំឯកសារដែលពាក់ព័ន្ធ ត្រូវប្រធានក្រុមប្រឹក្សាវិន័យ ធ្វើសេចក្តីសន្និដ្ឋានបញ្ជាក់ឱ្យបានច្បាស់លាស់នូវកំហុសដែលត្រូវចោទប្រកាន់ ព្រមទាំងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និងសម្រេច ។

ក្នុងករណីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនឯកភាព ក្រុមប្រឹក្សាវិន័យអាចចាត់ចៅក្រមដដែលឱ្យធ្វើការស៊ើបអង្កេតបន្ថែម ឬចៅក្រមផ្សេងទៀតដែលមានថ្នាក់ខ្ពស់ជាងចៅក្រមដែលមានរឿង ធ្វើការស៊ើបអង្កេតបន្ថែមលើចំណុចផ្សេងៗដែលខ្លួនយល់ឃើញថាមានការខ្វះខាត ឬមិនទាន់ច្បាស់លាស់ ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាវិន័យត្រូវលើកយកយោបល់របស់ខ្លួន ព្រមទាំងកំណត់ហេតុនៃការដាក់ទណ្ឌកម្មដែលមានចុះហត្ថលេខាដោយសមាជិកទាំងអស់ និងសំណុំរឿងជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងសម្រេចក្នុងអំឡុងពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ។ សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

ក្រសួងយុត្តិធម៌ ត្រូវរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យអំពីរឿងនេះ ថ្វាយព្រះមហាក្សត្រឡាយព្រះហស្ថលេខា ។

## ផ្នែកទី ៣
## ការចោទប្រកាន់តាមផ្លូវតុលាការ

### មាត្រា ៧២.-

ចៅក្រមដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ត្រូវទទួលការចោទប្រកាន់តាមផ្លូវតុលាការ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបញ្ជូនចៅក្រមដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ទៅតុលាការផ្សេងក្រៅពីតុលាការដែលចៅក្រមនោះបំពេញមុខងារ ។

### មាត្រា ៧៣.-

ចៅក្រមដែលទទួលការចោទប្រកាន់ជាស្ថាពរ ត្រូវផ្អាកមិនឱ្យបំពេញមុខងារជាបណ្តោះអាសន្នរហូតដល់មានសេចក្តីសម្រេចរបស់តុលាការអំពីទោសជាស្ថាពរ ។ ចៅក្រមនេះ ត្រូវទទួលប្រាក់បៀវត្សជាធម្មតារហូតដល់មានសាលក្រមសម្រេចរបស់តុលាការថាមានទោស ។ ប្រាក់បៀវត្សត្រូវផ្អាកជាបណ្តោះអាសន្ន ចាប់ពីថ្ងៃដែលសាលក្រមតុលាការសម្រេចថាមានទោស ទោះបីមានបណ្តឹងឧទ្ធរណ៍ពីសាលក្រមនេះ ក៏ដោយ ។

### មាត្រា ៧៤.-

ក្នុងករណីដែលចៅក្រមជាប់ចោទតាមផ្លូវតុលាការ ទទួលបានការលើកលែងចោទប្រកាន់ ឬត្រូវបានសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ជាស្ថាពរ ចៅក្រមនោះត្រូវបានទទួលឱ្យចូលធ្វើការវិញភ្លាម ដោយគិតពីអតីតភាព ថ្នាក់ និងឋានន្តរស័ក្តិ សោធននិវត្តន៍ និងទទួលប្រាក់បៀវត្សដែលត្រូវផ្អាកជាបណ្តោះអាសន្ន ពីមុនមកវិញទាំងអស់ ។

### មាត្រា ៧៥.-

ទោះបីមានសេចក្តីសម្រេចពីតុលាការ លើកលែងចោទប្រកាន់ក្តី ឬសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ក្តី ឬផ្តន្ទាទោសក្តី បើសាមីខ្លួនបានប្រព្រឹត្តខុសនឹងក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា សាមីខ្លួនអាចដាក់ឱ្យចោទប្រកាន់ជាបទវិន័យថែមទៀត ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## ជំពូកទី ១១
## ការដាក់ឱ្យនៅទំនេរ

### មាត្រា ៧៦.-

តាមពាក្យសុំរបស់សាមីខ្លួន ចៅក្រមទាំងឡាយអាចត្រូវបានអនុញ្ញាតឱ្យនៅទំនេរគ្មានបៀវត្សរយៈពេលម្តង ១ (មួយ) ឆ្នាំ ឬម្តង ២ (ពីរ) ឆ្នាំ ប៉ុន្តែមិនឱ្យលើសពី ៤ (បួន) ឆ្នាំ ។

លក្ខខ័ណ្ឌដែលអាចអនុញ្ញាតឱ្យនៅទំនេរគ្មានបៀវត្ស តាមការស្នើសុំរបស់សាមីខ្លួន បានលុះត្រាតែចៅក្រមនោះ បានបំពេញមុខងារក្នុងក្របខ័ណ្ឌដើមយ៉ាងតិចបាន ៤ (បួន) ឆ្នាំសិន ដោយមិនគិតពីចៅក្រមដែលត្រូវទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី ២ (ពីរ) ទេ ។

ការអនុញ្ញាតនេះ ត្រូវសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ៧៧.-**

ចៅក្រមដែលកំពុងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សលើកទី ១ (មួយ) បើមានបំណងសុំបន្ត ឬសុំចូលបម្រើការងារវិញ ត្រូវដាក់ពាក្យសុំឱ្យបាន ២ (ពីរ) ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។ ចៅក្រមណាពុំបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬពុំបានចូលបំពេញមុខងាររបស់ខ្លួនវិញនៅថ្ងៃចុងក្រោយនៃភាពទំនេរគ្មានបៀវត្សទេនោះ ត្រូវចាត់ទុកថាបានបោះបង់ការងារ ហើយត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌចាប់ពីថ្ងៃនោះតទៅ ឬដាក់ឱ្យចូលនិវត្តន៍ បើចៅក្រមនោះបានបំពេញលក្ខខណ្ឌ ចូលនិវត្តន៍ ។

**មាត្រា ៧៨.-**

ចៅក្រមដែលត្រូវបានបញ្ជូនទៅធ្វើកម្មសិក្សា ដើម្បីឱ្យមានសុក្រឹតភាពក្នុងវិជ្ជាជីវៈ ត្រូវចាត់ទុកដូចជាចៅក្រមដែលកំពុងបំពេញមុខងារ ។

## ជំពូកទី ១២
## ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ ប្រាក់ខ្ទង់ចៅក្រម និងការសម្រាកប្រចាំឆ្នាំ

**មាត្រា ៧៩.-**

ចៅក្រមត្រូវទទួលប្រាក់បៀវត្ស ដែលមានកំរិតតាមលំដាប់ថ្នាក់ និងឋានន្តរស័ក្តិរបស់ខ្លួន ។

**មាត្រា ៨០.-**

ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗដូចជា ប្រាក់បំណាច់ក្នុងកិច្ចការបំពេញបេសកកម្ម ប្រាក់បំណាច់ឈ្នួលផ្ទះ ប្រាក់បំណាច់អធិមូលជីវភាព ប្រាក់បំណាច់ស្នាក់នៅតំបន់ដាច់ស្រយាល ឬប្រកបដោយគ្រោះថ្នាក់ ប្រាក់បំណាច់ធ្វើដំណើរ និងស្នាក់អាស្រ័យ ប្រាក់បំណាច់ឆ្លងកាត់ ប្រាក់ថ្លៃព្យាបាលនៅក្នុងមន្ទីរពេទ្យ និងប្រាក់បំណាច់សម្រាប់ព្យាបាល

ជម្ងឺប្រចាំកាយរយៈពេលយូរ និងប្រាក់រង្វាន់ប្រចាំខែរបស់ចៅក្រម ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ចៅក្រមដែលត្រូវបានដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ពុំមានសិទ្ធិទទួលប្រាក់បំណាច់ផ្សេងៗ និងប្រាក់បំណាច់ប្រចាំខែ ដូចបានកំណត់ក្នុងកថាខ័ណ្ឌខាងលើឡើយ ។

**មាត្រា ៨១.-**

វិស្សមកាលតុលាការមានរយៈពេល ១ (មួយ) ខែ ។ វិស្សមកាលនេះ ត្រូវចាប់ផ្តើមពីថ្ងៃទី ១ ដល់ថ្ងៃទី ៣០ ខែមេសា ជារៀងរាល់ឆ្នាំ ។

នៅក្នុងអំឡុងពេលវិស្សមកាល តុលាការគ្រប់ជាន់ថ្នាក់ត្រូវរៀបចំចាត់ឱ្យមានការយាមប្រចាំការជានិរន្តរ ។ ការយាមប្រចាំការនេះត្រូវមានយ៉ាងតិច ចៅក្រមអាសនៈម្នាក់ ចៅក្រមអយ្យការម្នាក់ និងក្រឡាបញ្ជីម្នាក់ ដើម្បីត្រៀមចាត់ការនូវរាល់កិច្ចការប្រញាប់ និងចាំបាច់ ។

**មាត្រា ៨២.-**

ក្រៅពីវិស្សមកាលតុលាការ ចៅក្រមត្រូវមានរបបឈប់សម្រាកប្រចាំឆ្នាំ និងរបបឈប់សម្រាកផ្សេងៗ ចំនួន ១៥ (ដប់ប្រាំ) ថ្ងៃ ដូចដែលបានគ្រោងទុកសម្រាប់ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលដែរ ។

រយៈពេលធ្វើការដែលនាំឱ្យមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំនេះ ត្រូវគិតចាប់ពីថ្ងៃទី ១ ខែមករា ។

អាចសុំឈប់សម្រាកជាច្រើនដងក៏បាន ឬឈប់សម្រាកតែម្តងក្នុងមួយឆ្នាំក៏បាន ។ ការឈប់សម្រាកនេះ អាចបន្តរហូតផុតខែកុម្ភៈនៃឆ្នាំបន្ទាប់បាន ។

**មាត្រា ៨៣.-**

ចៅក្រមដែលបានបំពេញការងារបានគ្រប់ ២ (ពីរ) ឆ្នាំ មិនដែលមានអាក់ខាន ឬមានអាក់ខានដែរ ប៉ុន្តែបានបំពេញការងារគ្រប់បានចំនួន ២ (ពីរ) ឆ្នាំ អាចទទួលការអនុញ្ញាតឱ្យឈប់ដើម្បីទៅព្យាបាលជំងឺបានរយៈពេល ៦ (ប្រាំមួយ) ខែ ដោយមិនកាត់ប្រាក់បៀវត្ស ។

បើឈប់ដើម្បីទៅព្យាបាលជំងឺបន្តពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ ប្រាក់បៀវត្ស ត្រូវបន្ថយមកនៅត្រឹមពាក់កណ្តាល ។ បើត្រូវឈប់ដើម្បីទៅព្យាបាលជំងឺបន្ត

ថែមទៀតលើសពី ១ (មួយ) ឆ្នាំ ចៅក្រមនោះត្រូវទទួលប្រាក់ចូលនិវត្តន៍ ជាអតីតភាព ឬជាសមាមាត្រ ឬសុំបើកប្រាក់សោធនផ្តាច់តែម្តង ។ បើពុំអាចទទួលសិទ្ធិនេះបានទេ ត្រូវចាត់ទុកថាមានពិការភាព ដូចមានចែងក្នុងមាត្រា ២៧ ខាងលើ ។

ចៅក្រមដែលមានជំងឺ ហើយសុំឈប់សម្រាកព្យាបាល ត្រូវផ្តល់វិញ្ញាបនប័ត្រពេទ្យជាសេចក្តីបញ្ជាក់ ។ ប៉ុន្តែក្រសួងយុត្តិធម៌អាចឱ្យគ្រូពេទ្យជំនាញ ធ្វើការត្រួតពិនិត្យបានគ្រប់ពេលវេលា ប្រសិនបើយល់ឃើញថាជាការចាំបាច់ ។

**មាត្រា ៨៤.-**

ចំពោះចៅក្រមមិនបានឈប់សម្រាប់ប្រចាំឆ្នាំ រយៈពេលមិនបានឈប់នោះអាចយកទៅគិតបន្ថែមលើរយៈពេលព្យាបាលជំងឺខាងលើ ដោយមិនកាត់ប្រាក់បៀវត្ស ។

## ជំពូកទី ១៣
## ការចូលនិវត្តន៍

**មាត្រា ៨៥.-**

ចៅក្រមទាំងពីរភេទត្រូវចូលនិវត្តន៍នៅពេលគ្រប់អាយុ ៦០ (ហុកសិប) ឆ្នាំ ។

អាយុនេះអាចរំកិលបានរហូតដល់ ៦៥ (ហុកសិបប្រាំ) ឆ្នាំ តាមការចាំបាច់ ។ ការស្នើសុំបន្តការងារនេះ ត្រូវធ្វើឡើងមួយឆ្នាំម្តងៗ តាមការស្នើសុំរបស់សាមីខ្លួន ក្រោយពីមានការយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ៨៦.-**

ចៅក្រមដែលបានបម្រើការងារគ្រប់ ៣០ (សាមសិប) ឆ្នាំហើយ អាចសុំចូលនិវត្តន៍បានមុនគ្រប់អាយុ ៦០ (ហុកសិប) ឆ្នាំ ។

ចៅក្រមដែលបានបម្រើការងារលើសពី ៣០ (សាមសិប) ឆ្នាំ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍អតីតភាព ស្មើនឹង ១០០% នៃប្រាក់បៀវត្សចុងក្រោយ ។

ចៅក្រមដែលបានបម្រើការងារចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍សមាមាត្រស្មើនឹង ៨០% នៃប្រាក់បៀវត្សចុងក្រោយ ។

ចៅក្រមដែលបានបម្រើការងារចាប់ពី ២០ (ម្ភៃ) ឆ្នាំឡើងទៅ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍សមាមាត្រស្មើនឹង ៧០% នៃប្រាក់បៀវត្សចុងក្រោយ ។

ចៅក្រមដែលបានបម្រើការងារក្រោម ២០ (ម្ភៃ) ឆ្នាំ ត្រូវទទួលត្រឹមប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗតាមការកំណត់របស់រដ្ឋ ដូចមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋបាលដែរ ។

**មាត្រា ៨៧.~**

ក្រោយពេលដល់អាយុចូលនិវត្តន៍ហើយ ចៅក្រមដែលមានអតីតភាពគ្រប់ ៣០ (សាមសិប) ឆ្នាំ មិនត្រូវបានកាត់ប្រាក់សោធននិវត្តន៍ទុកទៀតឡើយ ក្នុងរយៈពេលបន្តការងារ ។ ប៉ុន្តែបើមានអតីតភាពមិនគ្រប់ ៣០ (សាមសិប) ឆ្នាំ នោះ ត្រូវកាត់ប្រាក់សោធននិវត្តន៍រហូតដល់មានអតីតភាពគ្រប់ចំនួន ៣០ (សាមសិប) ឆ្នាំ ដើម្បីបានទទួលប្រាក់សោធននិវត្តន៍អតីតភាព ។

**មាត្រា ៨៨.~**

អតីតភាពការងាររបស់ចៅក្រម ត្រូវគិតតាំងពីថ្ងៃដែលសាមីខ្លួនបានចូលបម្រើការងាររដ្ឋ ទោះក្នុងសម័យណាក៏ដោយ ។

**មាត្រា ៨៩.~**

ចៅក្រមដែលស្ថិតនៅក្នុងពិការភាព ដែលមិនអាចបំពេញការងារបន្តទៅទៀតបាន ហើយទុព្វលភាពនេះ បណ្តាលច្បាស់លាស់មកពីការបំពេញមុខងាររបស់ខ្លួន ឬបណ្តាលមកពីមនសិការខិតខំខ្លាំងទៅលើកិច្ចការដែលជាប្រយោជន៍សាធារណៈ ចៅក្រមនោះមានសិទ្ធិពិសេសត្រូវបានទទួលប្រាក់សោធននិវត្តន៍សម្រាប់ទុព្វលភាព ដែលមានចំនួនស្មើនឹងសោធននិវត្តន៍អតីតភាពដោយមិនគិតពីរយៈពេលបម្រើការងារ ។ ចៅក្រមនឹងអាចទទួលប្រាក់សោធននិវត្តន៍នេះបាន លុះត្រាតែមានជំងឺ ឬពិការភាពនោះ ជាមូលហេតុផ្ទាល់ហើយច្បាស់លាស់នៃទុព្វលភាព ឬអសមត្ថភាពបំពេញការងារ ។

មូលហេតុប្រភព ប្រភេទ និងស្លាកស្នាមនៃរបួស ឬជំងឺ ត្រូវតែមានបញ្ជាក់ដោយវិញ្ញាបនប័ត្រជាផ្លូវរដ្ឋបាល ចេញដោយអាជ្ញាធរមានសមត្ថកិច្ច និងវិញ្ញាបនប័ត្រពេទ្យ ចេញឱ្យដោយគណៈកម្មការកោសលវិច័យសុខាភិបាល ។

បើចៅក្រមទទួលមរណភាពមកពីការបម្រើការងារស្ថិតស្ថាញខាងលើ សហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងអនីតិភាពនៅឡើយ អាចទទួលប្រាក់បំណាច់ស្មើនឹងប្រាក់បៀវត្សសុទ្ធសាធរបស់អ្នកស្លាប់ចំនួន ១២ (ដប់ពីរ) ខែ ។

ក្រៅពីនេះ រដ្ឋត្រូវចិញ្ចឹមកូនដែលស្ថិតនៅក្នុងអនីតិភាព និងសហព័ទ្ធ ដូចមន្ត្រីរាជការចូលនិវត្តន៍ដទៃទៀតដែរ លើកលែងតែសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ជាថ្មី ។

## ជំពូកទី ១៤
## ងារជាកិត្តិយស

**មាត្រា ៩០.-**

នៅពេលចូលនិវត្តន៍ ចៅក្រមត្រូវទទួលបានឋានន្តរស័ក្តិមួយថ្នាក់ខ្ពស់ជាងឋានន្តរ-ស័ក្តិដែលខ្លួនកំពុងបំពេញសព្វថ្ងៃ កាលបើខ្លួនបានបំពេញការងារក្នុងឋានន្តរស័ក្តិនោះ បានយ៉ាងតិច ១ (មួយ) ឆ្នាំ មុនពេលចូលនិវត្តន៍ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកពិនិត្យ និងសម្រេចអំពីការផ្តល់ងារជាកិត្តិយសនេះ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៩១.-**

ងារជាកិត្តិយសនេះ ត្រូវធ្វើដោយព្រះរាជក្រឹត្យ ។

ចៅក្រមចូលនិវត្តន៍ មានសិទ្ធិពេញលេញនឹងរក្សាទុករហូតនូវងារជាកិត្តិយសនេះ ។

ងារជាកិត្តិយសនេះ អាចដកហូតវិញបាន ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលបើមានហេតុធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬសេចក្តីថ្លៃថ្នូររបស់អង្គចៅក្រម ។

## ជំពូកទី ១៥
## កិច្ចសច្ចាប្រណិធាន

**មាត្រា ៩២.-**

មុននឹងចូលបម្រើការងារ ចៅក្រមត្រូវធ្វើសច្ចាប្រណិធាន តាមព្រះពុទ្ធសាសនា នៅព្រះវិហារព្រះកែវមរកត ។

សម្បថត្រូវធ្វើទៅតាមការណែនាំ និងតាមរូបមន្តរបស់ប្រធានពិធីការ ក្រោមការចាត់ចែងរបស់ក្រសួងព្រះបរមរាជវាំង ។

**មាត្រា ៩៣.-**

ការធ្វើសម្បថខាងលើ ត្រូវមានកំណត់ហេតុធ្វើដោយមន្ត្រីព្រះបរមរាជវាំង ហើយត្រូវបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីតម្កល់ទុកក្នុងសំណុំលិខិតរបស់សាមីខ្លួន ។

**មាត្រា ៩៤.-**

ចៅក្រមណាដែលគេចវេះមិនព្រមធ្វើសម្បថ ឬមើលងាយរបៀបបញ្ចេញអាកប្ប-កិរិយា ឬបានសរសេរជាលាយលក្ខណ៍អក្សរ ឬពោលពាក្យតិះដៀល លើពាក្យសម្បថដែលខ្លួនបានស្បថរួចហើយ នោះត្រូវមានទោសជាវិន័យ ។

**មាត្រា ៩៥.-**

កាលបើត្រូវធ្វើជាសាក្សីនៅចំពោះមុខតុលាការ ចៅក្រមត្រូវធ្វើសម្បថតាមទំនៀមទំលាប់ នៃសាសនារបស់ខ្លួន និងតាមបែបបទរបស់តុលាការថែមទៀត ។

## ជំពូកទី ១៦
## អំពីឯកសណ្ឋានចៅក្រម

**មាត្រា ៩៦.-**

ឯកសណ្ឋានរបស់ចៅក្រមគ្រប់ថ្នាក់ រួមមានពីរប្រភេទគឺ÷

- ឯកសណ្ឋានក្នុងពេលជំនុំជម្រះ
- ឯកសណ្ឋានផ្លូវការក្នុងពិធីបុណ្យជាតិផ្សេងៗ ។

ឯកសណ្ឋានទាំងនេះ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ទៅតាមឋានន្តរស័ក្តិ និងថ្នាក់របស់ចៅក្រម ។

**មាត្រា ៩៧.-**

អាវផាយ និងមួក ជាឯកសណ្ឋានរបស់ចៅក្រមទាំងអស់ ដែលត្រូវពាក់នៅពេលជំនុំជម្រះ ។

អាវផ្លូវការ ជាឯកសណ្ឋានរបស់ចៅក្រមទាំងអស់ ដែលត្រូវពាក់ក្នុងពេលហែរក្បួន ឬក្នុងពីធីបុណ្យជាតិផ្សេងៗ បើមានតម្រូវជាផ្លូវការ ។

## ជំពូកទី ១៧
## ការចាត់ថ្នាក់ កិត្តិយស និងអាសនានុក្រម

**មាត្រា ៩៨.-**

ឋានានុក្រមនៃបណ្តាឋានន្តរស័ក្តិ និងថ្នាក់របស់ចៅក្រមជាហ្សិពាន់ មានដូចខាងក្រោម ÷

- ឧត្តមចៅក្រមថ្នាក់លេខ ១ ដល់លេខ ២ មានស័ក្តិ ១០ ហ្វូពាន់

- ឧត្តមចៅក្រមថ្នាក់លេខ ៣ ដល់លេខ ៤ មានស័ក្តិ ៩ ហ្វូពាន់
- វរៈចៅក្រមថ្នាក់លេខ ១ ដល់លេខ ២ មានស័ក្តិ ៨ ហ្វូពាន់
- វរៈចៅក្រមថ្នាក់លេខ ៣ ដល់លេខ ៤ មានស័ក្តិ ៧ ហ្វូពាន់
- អនុចៅក្រមថ្នាក់លេខ ១ ដល់លេខ ៣ មានស័ក្តិ ៦ ហ្វូពាន់
- អនុចៅក្រមថ្នាក់លេខ ៤ ដល់លេខ ៦ មានស័ក្តិ ៥ ហ្វូពាន់ ។

**មាត្រា ៩៩.-**

ចៅក្រមដែលមានស័ក្តិហ្វូពាន់ស្មើគ្នា ក្នុងថ្នាក់តែមួយត្រូវចាត់លំដាប់ថ្នាក់តាមថ្ងៃខែតែងតាំង ។ បើតែងតាំងក្នុងព្រះរាជក្រឹត្យជាមួយគ្នា ត្រូវបានចាត់ថ្នាក់តាមកំរិតអាយុ ។

## ជំពូកទី ១៨
## អន្តរប្បញ្ញត្តិ

**មាត្រា ១០០.-**

ក្រោយពីច្បាប់នេះចូលជាធរមាន ក្រសួងយុត្តិធម៌ត្រូវពិគ្រោះយោបល់ជាមួយឧត្តម-ក្រុមប្រឹក្សានៃអង្គចៅក្រម រៀបចំបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យលក្ខណៈវិនិច្ឆ័យចំណាត់ថ្នាក់ ឋានន្តរស័ក្តិចៅក្រមអាសនៈ និងចៅក្រមអយ្យការ ដែលបានតែងតាំងរួចហើយ និងដែលកំពុងបំពេញមុខងារ ។

គណៈកម្មការនេះ ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ១៩
## អវសានប្បញ្ញត្តិ

**មាត្រា ១០១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។